ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃជំនួបតាមប្រព័ន្ធវីដេអូរវាងនាយករដ្ឋមន្ត្រីប្រទេសទាំងបី ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង សាធារណរដ្ឋសង្គមនិយមវៀតណាម
# ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមបណ្ឌិត ថងលុន ស៊ីសុលិត នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ឯកឧត្តម ង្វៀន សួនហ៊ុក នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានជួបគ្នាតាមប្រព័ន្ធវីដេអូ ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងបី ក្នុងក្របខ័ណ្ឌទ្វេភាគី ត្រីភាគី និងពហុភាគី។

នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគំនិតផ្តួចផ្តើមដ៏សំខាន់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ឱ្យមានជំនួបតាមប្រព័ន្ធវីដេអូ ដែលជាការរួមចំណែកពង្រឹង និងពង្រីកបន្ថែមទៀតនូវមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កានៃប្រទេសទាំងបី។

នៅក្នុងអំឡុងជំនួបនេះ នាយករដ្ឋមន្ត្រីទាំងបីបានជម្រាបជូននូវសភាពការណ៍វិវត្តន៍ថ្មីៗនៅក្នុងប្រទេសរបស់ខ្លួន រួមទាំងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានសម្តែងការអបអរសាទរសមភាគីវៀតណាម និងឡាវ ចំពោះភាពជោគជ័យនៃមហាសន្និបាត នៃបក្សកុម្មុយនីស្តវៀតណាម លើកទី១៣ មហាសន្និបាតនៃបក្សបដិវត្តន៍ប្រជាជនឡាវ លើកទី១១ ក៏ដូចជាការបោះឆ្នោតមហាសន្និបាតជាតិឡាវ។ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានកោតសរសើរវៀតណាមដែលទទួលបានជោគជ័យក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៅឆ្នាំ២០២០ ទោះបីជាមានការរីករាលដាលជំងឺកូវីដ-១៩ ក៏ដោយ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh